# គោលនយោបាយស្ដីពីកាំបិតនៅសាលារៀន

ជូនចំពោះឪពុកម្ដាយ និងអ្នកថែទាំ

រដ្ឋាភិបាលរដ្ឋ NSW ថ្មីៗនេះ បានធ្វើការពិគ្រោះយោបល់ជាមួយសហគមន៍ ដោយធ្វើការយ៉ាងជិតស្និទ្ធ ជាមួយមេដឹកនាំសហគមន៍ Sikh និងអ្នកជំនាញសុខភាព និងសុវត្ថិភាព ដើម្បីពិនិត្យឡើងវិញនូវគោលនយោបាយស្ដីពីកាំបិតនៅសាលារៀន។

ក្រសួងសូមថ្លែងអំណរគុណដល់សមាជិកសហគមន៍ទាំងអស់ ដែលបានបញ្ចេញមតិរបស់ពួកគេ ក្នុងអំឡុងពេលពិគ្រោះយោបល់ និងអ្នកដែលបានជួយក្នុងការបង្កើតគោលការណ៍ណែនាំដែលបានកែសម្រួលឡើងវិញ ដែលកំណត់ពីកាលៈទេសៈដែលសិស្សម្នាក់ អាចមានកាំបិតនៅសាលារៀន។

គោលការណ៍ណែនាំទាំងនេះ  ឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តរបស់ក្រសួង ក្នុងការធ្វើអ្វីដែលអាចធ្វើទៅបាន ដើម្បីការពារសិស្ស និងបុគ្គលិកពីហានិភ័យដែលអាចគ្រោងទុកជាមុន ចំពោះសុខភាព និងសុវត្ថិភាពរបស់ពួកគេ ហើយនិងការប្ដេជ្ញាចិត្តរបស់ខ្លួនក្នុងការគោរពភាពផ្សេងៗគ្នានៃសហគមន៍រដ្ឋ NSW ហើយជៀសវាងអំពើរើសអើងដែលខុសច្បាប់។

ការហាមឃាត់មិនឱ្យមានកាំបិតនៅសាលារៀន នៅតែជាធរមាន ប៉ុន្តែមិនរារាំងសិស្សពីការពាក់ Kirpan ទេ ដរាបណាពួកគេគោរពតាមគោលការណ៍ណែនាំថ្មីដែលតឹងរ៉ឹង។ Kirpan គឺជាវត្ថុមួយដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកាំបិតដែលពាក់ដោយអ្នកកាន់សាសនា Sikhs ដែលបានទទួលបុណ្យជ្រមុជទឹក ជាវត្ថុនៃជំនឿរបស់ពួកគេ ហើយមានន័យខាងសាសនាយ៉ាងសំខាន់។

ដើម្បីឱ្យសិស្សកាន់សាសនា Sikhs ដែលបានទទួលបុណ្យជ្រមុជទឹក ត្រូវបានអនុញ្ញាតឱ្យពាក់ Kirpan នៅសាលារៀន Kirpan នោះត្រូវតែ៖

- ត្រូវមានទំហំតូច ប្រវែងពេញ 16.5 សម (ប្រហែល 6.5 អ៊ីញ) ឬតិចជាងនេះដោយគ្មានគែម ឬចុងមុតស្រួច
- មានផ្លែកាំបិតដាក់ការពារជាប់នៅក្នុងស្រោម ដើម្បីកុំឱ្យវាដកចេញបាន
- ត្រូវពាក់នៅក្រោមសម្លៀកបំពាក់ ហើយចងជាប់ដើម្បីកុំឱ្យយកប្រើបាន
- ត្រូវយកចេញ ហើយរក្សាទុកដោយសុវត្ថិភាព ឬ “ចងជាប់ទៅនឹងដងខ្លួន” នៅពេលធ្វើសកម្មភាពរាងកាយដូចជាកីឡា។

**កំណត់ចំណាំ៖** “ចងជាប់ទៅនឹងដងខ្លួន” មានន័យថា រុំក្នុងក្រណាត់រឹងមាំ ហើយចងជាប់ក្នុងខ្សែយឺតកីឡា (sports band) ឬខ្សែក្រវ៉ាត់ស្បែក ដែលធានាថាវាមិនអាចរបូតចេញ ឬបង្ករបួសដល់អ្នកពាក់ ឬមនុស្សផ្សេងទៀត។

នៅពេលត្រូវបានសួរដោយសមហេតុផល សិស្សត្រូវតែបញ្ជាក់ថា គោលការណ៍ណែនាំទាំងនេះកំពុងត្រូវបានអនុលោមតាម។ រាល់កង្វល់អំពីសុវត្ថិភាពណាមួយ នឹងត្រូវបានពិភាក្សាជាមួយសិស្ស និងឪពុកម្ដាយ ឬអ្នកថែទាំរបស់ពួកគេ។

ខណៈដែលសិស្សកាន់សាសនា Sikhs ដែលបានទទួលបុណ្យជ្រមុជទឹកអាចពាក់ Kirpan ពួកគេមិនបានអនុញ្ញាតឱ្យប្រើវានៅសាលារៀន ក្នុងគោលបំណងណាមួយឡើយ។

សិស្សមិនបានអនុញ្ញាតឱ្យមានកាំបិតនៅសាលារៀន ក្នុងកាលៈទេសៈណាផ្សេងទៀតឡើយ លុះត្រាតែកាំបិតនោះកំពុងត្រូវបានប្រើសម្រាប់គោលបំណងអប់រំ (ឧទាហរណ៍ ក្នុងអំឡុងថ្នាក់អនុវត្តបច្ចេកវិទ្យាអាហារ)។

សិស្សដែលអាចយកកាំបិតមកសាលារៀន ដោយហេតុថាពួកគេកំពុងចូលរៀននៅថ្នាក់ TAFE បន្ទាប់ពីសាលារៀន ត្រូវតែប្រគល់កាំបិតនៅក្នុងប្រអប់ ឬស្នៀតកាំបិតនៅការិយាល័យសាលា នៅដើមថ្ងៃ ហើយប្រមូលវាវិញនៅចុងថ្ងៃ។

ព័ត៌មានបន្ថែមអំពីគោលការណ៍ណែនាំថ្មីនេះ អាចរកបាននៅ https://education.nsw.gov.au/about-us/rights-and-accountability/legal-issues-bulletins/knives-in-schools

ដោយក្តីគោរព

នាយកសាលា (Principal)

**សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ**

ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម ហើយអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទមក សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ សូមប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ ដើម្បីជួយអ្នកក្នុងការសន្ទនា។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។